**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិបណ្តុះបណ្តាល**

National Training Board (NTB)

# កំណត់ហេតុប្រជុំ
# គណៈកម្មាធិការជាតិបណ្តុះបណ្តាល

ឆ្នាំពីរពាន់ប្រាំបី ខែមករា ថ្ងៃទីម្ភៃមួយ វេលាម៉ោងប្រាំ រសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ។

**សមាសភាពអញ្ជើញចូលរួម :**

-សមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាលចំនួន ៣២ រូប ( អវត្តមានចំនួន ០៦ រូប និងលោក លោកស្រីអញ្ជើញមកចូលរួមប្រជុំជំនួសចំនួន ០៤ រូប)

-លេខាធិការចំនួន ០៥ រូប

-តំណាងអ្នកពាក់ព័ន្ធចំនួន ១០ រូប ( អវត្តមានចំនួន ០២ រូប )

-មន្ត្រីជំនាញចំនួន ០៧ រូប

**របៀបវារៈនៃអង្គប្រជុំមាន :**

១-ប្រកាសបើកអង្គប្រជុំដោយ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

២-របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ឆ្នាំ២០០៦ និងឆ្នាំ២០០៧

-ផែនការជាតិអភិវឌ្ឍន៍ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០០៨

( លោក តឹប អឿន អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ )

៣- រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល

- សំណើសុំបង្កើតភ្នាក់ងារជាតិមុខរបរ (National Employment Agency)

( ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជានាយកគម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី ២ (ESDP II) )

៤- គេហទំព័ររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB’s Website) ( លោក ញឹប ចំរើន )

៥-បង្កើនសិស្សដែលបានបញ្ចប់ការសិក្សាចំណេះទូទៅកំរិតទុតិយភូមិឱ្យចូលរៀននៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

( ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជានាយកគម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី២ (ESDP II) )

៦- ផ្សេងៗ

**របៀបវារៈទី ១ :**

ជាកិច្ចចាប់ផ្តើមនៃកិច្ចប្រជុំ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍លើកយកបញ្ហាពាក់ព័ន្ធលើគុណភាពបណ្តុះបណ្តាលដើម្បីឱ្យមានជំនាញជាក់លាក់ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរកការងារធ្វើ និងប្រកបអាជីពផ្ទាល់ខ្លួន ហើយឯកឧត្តមឧបនាយករដ្ឋមន្ត្រីមានបំណងចង់ឱ្យសិស្សបានបញ្ចប់នៅសាលាចំណេះទូទៅចូលរៀននៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យបានច្រើន ព្រោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានតួនាទីសំខាន់ណាស់ក្នុងការបណ្តុះបណ្តាលកម្មករជំនាញ អ្នកបច្ចេកទេសដែលទីផ្សារបច្ចុប្បន្នត្រូវការជំនាញច្រើនជាងអ្នកគ្រប់គ្រង ។

ដូច្នេះយើងត្រូវត្រៀមលក្ខណៈរួចជាស្រេចក្នុងការបណ្តុះបណ្តាលជំនាញឱ្យសមស្របទៅនឹងតម្រូវការទីផ្សារពលកម្មបច្ចុប្បន្ន ។

**របៀបវារៈទី ២ :**

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំក៏បានអនុញ្ញាតឱ្យ លោក តឹប អឿន ធ្វើការបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់នៅឆ្នាំ២០០៦ និង ឆ្នាំ២០០៧ :

-នៅឆ្នាំ ២០០៦ បានធ្វើការបណ្តុះបណ្តាលលើខេត្តចំនួនពីរ គឺ :

- ខេត្តបាត់ដំបងបានបណ្តុះបណ្តាលចំនួន ២៩ ឃុំ ក្នុងស្រុក ៧ ដែលមានសិស្សសរុបចំនួន ៧.០១៧ នាក់ ក្នុងនោះមានសិស្សស្រី ៣.៥១៥ នាក់
- ខេត្តកំពត បានធ្វើការបណ្តុះបណ្តាលចំនួន ៣២ ឃុំក្នុងស្រុក ៨ ដែលមានសិស្សសរុប ៧.២៨០ នាក់ ក្នុងនោះមានសិស្សស្រី ៣.៦១៥ នាក់

ជារួមការបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ក្នុងឆ្នាំ២០០៦ មាន ៦១ ឃុំ ក្នុងស្រុក ១៥ មានសិស្សសរុបចំនួន ១៤.២៩៧ នាក់ ក្នុងនោះមានសិស្សស្រី ៧.១៣០ នាក់ ត្រូវជា ៥៩.៨៧ ភាគរយនៃចំនួនសិស្សសរុប ។

ហើយការបណ្តុះបណ្តាលបានចែកចេញជា ***០៣ ផ្នែក*** គឺ :

- ការបណ្តុះបណ្តាលតាមសហគមន៍
- ការបណ្តុះបណ្តាលតាមសហគ្រាស
- ការបណ្តុះបណ្តាលតាមមជ្ឈមណ្ឌល

-នៅឆ្នាំ ២០០៧ បានធ្វើការបណ្តុះបណ្តាលបន្ថែមចំនួន ៥ ខេត្ត បន្ថែមសរុបគឺចំនួន ០៧ ខេត្ត :

- ខេត្តបាត់ដំបង បានធ្វើការបណ្តុះបណ្តាលចំនួន ២៩ ឃុំក្នុងស្រុក ៧ ដែលមានសិស្សសរុប ៦.៥០២ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ៤.០៧៣ នាក់
- ខេត្តកំពត បានធ្វើការបណ្តុះបណ្តាលចំនួន ៣២ ឃុំ ក្នុងស្រុក ៨ ដែលមានសិស្សសរុប ៧.១១២ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ៤.២៦៦ នាក់
- ខេត្តកំពង់ឆ្នាំង បានធ្វើការបណ្តុះបណ្តាលចំនួន ២៦ ឃុំ ក្នុងស្រុក ៨ ដែលមានសិស្សសរុប ៥.៧៧២ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ២.៨៤០ នាក់
- ខេត្តសៀមរាប បានធ្វើការបណ្តុះបណ្តាលចំនួន ៣៩ ឃុំ ក្នុងស្រុក ៩ ដែលមានសិស្សសរុប ៨.៦៥៨ នាក់ ក្នុងនោះមានសិស្សស្រី ៥.៩៧១ នាក់

- ខេត្តស្ទឹងត្រែង បានធ្វើការបណ្តុះបណ្តាលបានចំនួន ១៤ ឃុំ ក្នុងស្រុក ៥ ដែលមានសិស្សសរុប ២.៨០០ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ១.៧៣២ នាក់
- ខេត្តស្វាយរៀង បានធ្វើការបណ្តុះបណ្តាលបានចំនួន ៣១ ឃុំ ក្នុងស្រុក ៧ ដែលមានសិស្សសរុប ៦៨៨២ នាក់ ដែលមានសិស្សស្រី ៣.២១១ នាក់
- ខេត្តតាកែវ បានធ្វើការបណ្តុះបណ្តាលបានចំនួន ៣៩ ឃុំ ក្នុងស្រុកចំនួន ៩ ដែលមានសិស្សសរុប ៨.៦៥៨ នាក់ ក្នុងនោះមានសិស្សស្រី ៣.៧៩៦ នាក់។

សរុបមកសំរាប់ឆ្នាំ ២០០៧ បណ្តុះបណ្តាលបានចំនួន ៤៦.៣៨៤ នាក់ក្នុងនោះមានស្រី ២៥.៨៨៩ នាក់ត្រូវជា ៥៥.៨១ ភាគរយ។

ដូចនេះ ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ក្នុងឆ្នាំ២០០៦ និង ឆ្នាំ២០០៧ គឺបណ្តុះបណ្តាលបានចំនួន ០៧ ខេត្ត ក្នុងស្រុក ៥៣ ដែលមានចំនួន ២១០ ឃុំ សិស្សសរុបចំនួន ៦០.៦៨១ នាក់ ក្នុងនោះមានស្រី ៣៣.០១៩ នាក់ ត្រូវជា ៥៤.៤១ ភាគរយ។

**ឯកឧត្តម សុខ អាន :**

បន្ទាប់ពីបានស្តាប់ការធ្វើបទបង្ហាញរបស់ លោក តឹប អឿន ឯកឧត្តមប្រធាន NTB បានអនុញ្ញាតឱ្យបញ្ជាក់ពីដំណើរការបណ្តុះបណ្តាលប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

**លោកតឹប អឿន :**បានបកស្រាយអំពីការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ បានចែកចេញជា***០៣***ផ្នែកៈ

-ការបណ្តុះបណ្តាលផ្អែកតាមសហគ្រាស (បញ្ជូនសិក្ខាកាមទៅរៀនផ្ទាល់នៅតាមសហគ្រាស)

-ការបណ្តុះបណ្តាលតាមតម្រូវការសហគមន៍ (ផ្នែកកសិកម្ម : ចិញ្ចឹមមាន់ ទា ជ្រូក ដំណាំបន្លែ...)

-ការបណ្តុះបណ្តាលផ្អែកតាមមជ្ឈមណ្ឌល (សេវាកម្ម : ផ្នែកជួសជុលម៉ាញ៉េ ម៉ូតូ ម៉ាស៊ីនធនតូច, រថយន្ត...)

**ឯកឧត្តម ពេជ សោភ័ន :**

បានលើកបន្ថែមអំពីការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ដែលត្រូវបានបង្កើតឡើងទៅតាមនិន្នាការថ្មីនៃទីផ្សារការងារ និងយោងតម្រូវការទីផ្សារដែលមានជាង ៣០ ម៉ឺននាក់ ត្រូវការបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ ហើយសាលាទាំងឧត្តមសិក្សា ទាំងបណ្តុះបណ្តាលវិជ្ជាជីវៈអាចស្រូបយកបានតែជាង ២០ ម៉ឺននាក់ប៉ុណ្ណោះ។ ដូច្នេះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើរតួនាទីសំខាន់ដើម្បីឆ្លើយតបទៅនឹងបញ្ហាបណ្តុះបណ្តាលមុនគេព្រោះថា TVET មានមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅតាមខេត្ត-ក្រុង ចំនួន ២២ ក្នុងនោះខេត្តមួយចំនួនបានប្រែក្លាយទៅជាវិទ្យាស្ថាន ដើម្បីធ្វើការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលដូចជាខេត្តបាត់ដំបង ។ TVET បានដើរតួនាទីសំខាន់ក្នុងការផ្តល់ជំនាញដល់ប្រជាពលរដ្ឋឱ្យមានអាជីព ក៏ដូចជាមានការងារធ្វើ ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា។ ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់មាន ***៣ផ្នែក*** គឺការបណ្តុះបណ្តាលផ្អែកតាមសហគ្រាស ការបណ្តុះបណ្តាលផ្អែកតាមតម្រូវការសហគមន៍ និងការបណ្តុះបណ្តាលផ្អែកតាមមជ្ឈមណ្ឌល។

ក្នុងនោះដែរ យើងអនុវត្តការបណ្តុះបណ្តាលជំនាញប្រព័ន្ធតាមលិខិតបញ្ជាក់ ក្នុងគោលដៅទីមួយធ្វើវិមជ្ឈការគឺមានន័យថាផ្តល់សិទ្ធិឱ្យមូលដ្ឋានជាអ្នកធ្វើផែនការក្នុងការបណ្តុះបណ្តាលជំនាញនៅតាមសហគមន៍របស់ខ្លួន ដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដើរតួរជាអ្នកបង្ហាត់បង្រៀន ផ្តល់សិទ្ធិឱ្យក្រុមប្រឹក្សាឃុំជ្រើសរើសភូមិធ្វើការបណ្តុះបណ្តាល ក៏ដូច

ជាបង្អាត់ឱ្យឃុំចេះធ្វើអង្កេតក្នុងឃុំរបស់ខ្លួន រីឯបញ្ហាថវិកាបណ្តុះបណ្តាល ឃុំជាអ្នករៀបចំគ្រប់គ្រង ទីពីរគឺបង្កើនចំនួនបណ្តុះបណ្តាល ទីបីគឺធ្វើឱ្យការបណ្តុះបណ្តាលឆ្លើយតបនឹងសេចក្តីត្រូវការពិតប្រាកដរបស់សហគមន៍មូលដ្ឋាន។

**ប្រធានអង្គការ** UNESCO **:** បានលើកឡើងពីប្រវត្តិនៃការសិក្សារបស់គាត់កាលពីក្មេងដែលធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅវិទ្យាល័យដែលមានលក្ខណៈជាបច្ចេកទេសច្រើន។ ស្ថានការនៅជប៉ុនកាលនោះគឺប្រហាក់ប្រហែលនឹងស្ថានភាពកម្ពុជាបច្ចុប្បន្ន ហើយដែលជាតំរូវការចាំបាច់ត្រូវពង្រីកឱកាសដល់សិស្សដែលរៀនចប់បាក់ឌុបបានចូលរៀនជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបានជំនាញ ហើយគាត់ក៏បានចាប់អារម្មណ៍ពីការបណ្តុះបណ្តាលរបស់ TVET នៅក្នុងប្រទេសកម្ពុជាដែរ ព្រោះវាផ្តល់ជំនាញដល់ប្រជាជនឱ្យមានការងារធ្វើ។ ចំពោះមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមខេត្តភាគច្រើនផ្តោតតែទៅលើវិស័យកសិកម្ម ហើយក៏មិនត្រូវភ្លេចដែរអំពីបច្ចេកវិទ្យាព័ត៌មានវិទ្យា ICT ជួសជុលគ្រឿងចក្រសំណង់ និងជំនាញផ្សេងៗ ក្នុងនោះលោកក៏បានលើកយកបញ្ហាភាសាបរទេស ក៏ជាយានក្នុងការពង្រីកចំណេះដឹង និងស្វែងយល់ពីបច្ចេកវិទ្យាថ្មី ដើម្បីកែច្នៃអាជីពឱ្យកាន់តែប្រសើរឡើង ។ លោកពិតជាមានការចាប់អារម្មណ៍យ៉ាងខ្លាំងអំពី TVET ហើយលោកបានណែនាំឱ្យមើលសៀវភៅដែលចងក្រងដោយ ILO និង UNESCO ស្តីអំពីការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ TVET ក្នុងសតវត្សទី ២១ និងនិយាយពីការណែនាំ ការតាក់តែងគោលនយោបាយកំណត់ចក្ខុវិស័យអំពីការបែងចែកការងារនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**ឯកឧត្តម សុខ អាន :**

បានថ្លែងអំណរគុណដល់ប្រធាន UNESCO ដែលបានផ្តល់អនុសាសន៍ល្អៗ ហើយឯកឧត្តមប្រធានបានអនុញ្ញាតឱ្យបង្ហាញនូវរបៀបវារៈបន្ត :

**លោក តឹប អឿន :** បានបង្ហាញពីលទ្ធផលនៃការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅឆ្នាំ២០០៦-២០០៧

- ឆ្នាំ២០០៦ TVET បានធ្វើការបណ្តុះបណ្តាលដែលមានចំនួនសរុប ២៧.៩៦៧ នាក់
  - មធ្យមបច្ចេកទេស និងឧត្តមសិក្សា ដែលមានសិស្សបានបញ្ចប់ចំនួន ២.១៦៤ នាក់
  - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតាមខេត្ត (NTF /PB) ដែលមានចំនួន ១១.៥០៦ នាក់
  - ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ៧ PTCs ដែលមានចំនួន ១៤.២៩៧ នាក់
- ឆ្នាំ២០០៧ TVET បានធ្វើការបណ្តុះបណ្តាលដែលមានសិស្សសរុប ៦៩.៤៧១ នាក់
  - មធ្យមបច្ចេកទេស និង ឧត្តមសិស្សបានបញ្ចប់ ៣.៤៩៧ នាក់
  - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតាមខេត្ត (NTF /PB) បានចំនួន ១៩.៥៩០ នាក់
  - ការបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ៧ PTCs បានចំនួន ៤៦.៣៨៤ នាក់

លទ្ធផលដែលសម្រេចបាននៅឆ្នាំ២០០៦-២០០៧ ដូចជាៈ

-ការងារចាត់ចែងផ្ទៃក្នុងគឺជាលទ្ធផលការងារដែលមានការចាត់តាំងមានការបញ្ជាក់ច្បាស់លាស់

-ការគ្រប់គ្រងបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធលិខិតបញ្ជាក់ ដោយអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត គឺមានភាពរឹងប៉ឹង

-ចំនួនសិស្សបានបញ្ចប់ការសិក្សានៅប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺមានការកើនឡើង

-សហគមន៍អន្តរជាតិមានការចាប់អារម្មណ៍ខ្លាំង នៅក្នុងកម្មវិធីជាវិជ្ជមានជាមួយនឹងអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដូចដែលយើងបានបង្ហាញការចាត់ចែងការឧបត្ថម្ភគាំទ្រដែលមានការប្រសើរឡើងយ៉ាងខ្លាំង

**លោក តិប អឿន :**បានបន្តបង្ហាញអំពីអនុសាសន៍សម្រាប់អនុវត្តឆ្នាំ២០០៨ ដែលមាន ៧ ចំនុច ដូចខាងក្រោម :

-ពង្រឹងទំនាក់ទំនងរវាង TVET និង សហគ្រាស ( TVET តាមតម្រូវការទីផ្សារ ) និងអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

-បង្កើនល្បឿនអភិវឌ្ឍន៍ស្តង់ដាសមត្ថភាពសំរាប់ផ្នែកសំលៀកបំពាក់ បដិសណ្ឋារកិច្ច និងកសិពាណិជ្ជកម្ម

-ផ្សារភ្ជាប់គ្នារវាងនិយោជក អ្នកដែលប្រើប្រាស់កំលាំងពលកម្ម និងអ្នកដែលស្វែងរកការងារធ្វើ

-រៀបចំដំណើរការ (National Levy Grant System ) ដើម្បីជួយផ្តល់ហិរញ្ញប្បទានសំរាប់ TVET

-ធ្វើសកម្មភាពបង្កើនចំនួនសិស្សបញ្ចប់ពីសាលាចំណេះទូទៅកំរិតទុតិយភូមិ ដែលបានចុះបញ្ជីឈ្មោះក្នុងកម្មវិធី TVET កំរិតមធ្យមបច្ចេកទេស និងឧត្តម មានការកើនឡើង

-រៀបចំដំណើរការNational Bridging Programដើម្បីជួយយុវជនដែលចូលមកក្នុងគ្រឹះស្ថានTVETមាន លទ្ធភាពបន្ត

-ពង្រីកការគាំទ្រពីអន្តរជាតិសំរាប់កម្មវិធី TVET ដើម្បីសំរេចអនុសាសន៍ទាំងអស់នេះ

**ឯកឧត្តម សុខ អាន :**

ឯកឧត្តមប្រធាន បានលើកឡើងពីទំនាក់ទំនងរវាងអ្នកប្រើប្រាស់កំលាំងពលកម្ម និងទីផ្សារពលកម្មដោយពឹងផ្អែកលើប្រព័ន្ធព័ត៌មានទីផ្សារ ដើម្បីឱ្យអ្នកត្រូវការកំលាំងពលកម្មទទួលយកអ្នកស្វែងរកការងារ តាមរយៈការបង្កើតមជ្ឈមណ្ឌលស្វែងរកការងារធ្វើ( Job Centers) ដែលជាយន្តការមួយយ៉ាងសំខាន់ដោយឆ្លងកាត់កម្មវិធីបំពាក់បំប៉នពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ឯកឧត្តមប្រធាន បានចាប់អារម្មណ៍ដោយធ្វើយ៉ាងណាឱ្យសិស្សបណ្តុះបណ្តាលរួច មានការងារធ្វើ ហើយបានការចូលរួមពីសំណាក់ឯកជនក្នុងការទទួលយកសិស្សបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**ឯកឧត្តម សុន ចន្ធរ ប្រធានសភាចុងរបរ និងមីក្រូសហគ្រាស :**

ឯកឧត្តម មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការរៀបចំបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ជាពិសេសចំពោះការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលឯកឧត្តម ពេជ សោភ័ន បានលើកចំនុចសំខាន់ៗ និងអនុសាសន៍ល្អៗ ។ ឯកឧត្តម បានលើកបញ្ហាប្រទេសបារាំង អាហ្វ្រិច អំពីការបណ្តុះបណ្តាលរួចមានការងារធ្វើដោយអ្នកមានកំរិតជំនាញបច្ចេកទេសទទួលបានប្រាក់ខែច្រើនជាងកំរិតឧត្តម ព្រោះថាកំរិតជំនាញទទួលបានបទពិសោធន៍ និងជាតម្រូវការដែលគេត្រូវការជាងកំរិតឧត្តម ។ ឯកឧត្តម ក៏បានបញ្ជាក់ដែរថា បច្ចេកទេសវាសំខាន់ក្នុងការទទួលយកការងារ រីឯចំណេះដឹងទូទៅគឺមិនត្រូវចោលដែរ ព្រោះជាចំណេះមូលដ្ឋានសំរាប់ស្រាវជ្រាវ ហើយទីផ្សារកម្ពុជាសព្វថ្ងៃត្រូវការជំនាញបច្ចេកទេសជាងនិស្សិតដែលបញ្ចប់ឧត្តមសិក្សា ។ ក្នុងនោះឯកឧត្តម ក៏បានលើកពីបញ្ហាបណ្តុះបណ្តាលជំនាញឱ្យសមស្របនឹងតម្រូវការទីផ្សារការងារ និងការសហការណ៍ជាមួយសហគ្រាសសាធារណៈ ដើម្បីទំនាក់ទំនងក្នុងការបណ្តុះបណ្តាលជំនាញឱ្យមានការងារធ្វើ។ គ្រប់អង្គភាពសហគ្រាស NGOs សុទ្ធតែត្រូវការបណ្តុះបណ្តាល ដូចនេះត្រូវតែសហការណ៍សម្របសម្រួលជាមួយបណ្តាអង្គភាពទាំងនេះដើម្បីទទួលការបណ្តុះបណ្តាលរួចសិស្សមានការងារធ្វើនៅតាមសហគ្រាស ឬ អាចបង្កើតសហគ្រាសខ្នាតតូច និងមធ្យមតែម្តង។ ឯកឧត្តម ក៏បានសសើរចំពោះការបង្កើតឱ្យមានគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងអាចមានដំណើរការ

បានយ៉ាងល្អ ដោយសារមានការចូលរួមពីសហគ្រាសឯកជន ព្រោះថាការបណ្តុះបណ្តាលសំខាន់ណាស់សម្រាប់ឱ្យមានជំនាញវិជ្ជាជីវៈ។ ឯកឧត្តម ក៏បានចាប់អារម្មណ៏ដែរ ពីបញ្ហាបណ្តុះបណ្តាលហើយសិក្ខាកាមពុំមានលទ្ធភាពបើកមុខរបររបស់ខ្លួនដោយសារគ្មានទុន ។ ដូចនេះវាទាមទារឱ្យមានឥណទានខ្នាតតូចសំរាប់ផ្តល់ប្រាក់កម្ចីដល់ពួកគេ និងព័ត៌មានទីផ្សារការងារស្តង់ដាជាតិសមត្ថភាព និងសហគ្រាសខ្នាតតូចក្នុងការងាយស្រួលឱ្យពួកគេមានការងារធ្វើគ្រប់គ្នាបន្ទាប់ពីបណ្តុះបណ្តាលរួច។

**ឯកឧត្តម សុខ អាន :**

បានលើកឡើង ០២ ចំនុច គឺអំពីការខ្វះខាត និងខ្វះការសម្របសម្រួលនៅតាមសហគ្រាសរវាងឯកជន និងរដ្ឋ ។

**ឯកឧត្តម អ៊ុក សូម៉េត :**

បានចាប់អារម្មណ៏អំពីកំលាំងពលកម្មដែលបានបំរើឱ្យវិស័យសេដ្ឋកិច្ចជាខ្លាំងបើតាមឯកឧត្តមបានអង្កេត រីឯបញ្ហាបច្ចេកទេសនៅតាមវិទ្យាល័យដែលសិស្សបានបញ្ចប់ការសិក្សា អាចមានជំនាញតែម្តងក្នុងការក្លាយជាកម្មករជំនាញសម្រាប់សហគ្រាស ហើយធ្វើការងារបានយ៉ាងល្អទៀត ប៉ុន្តែពួកគេមិនអាចគិតពីការងារធំដូចពួកវិស្វករបានទេ។ ឯកឧត្តម បានលើកពីបទពិសោធន៏នានាទាក់ទងនឹងបរទេសអំពីការដូរទស្សនវិស័យពីថ្នាក់វិស្វករមកថ្នាក់ជំនាញបច្ចេកទេសវិញ ព្រោះការរស់នៅពេលអនាគតគឺត្រូវការជំនាញបច្ចេកទេសខ្លាំងណាស់សំរាប់អភិវឌ្ឍន៏សេដ្ឋកិច្ច រីឯថ្នាក់វិស្វករក៏ទាមទារឱ្យចេះធ្វើទីផ្សារដែរដើម្បីលក់ផលិតផលរបស់ខ្លួន ។ ចំពោះអ្នកដែលរៀនជំនាញបច្ចេកទេសអាចមានឱកាសចូលរៀននៅតាមសាកលវិទ្យាល័យបច្ចេកទេស ដើម្បីបង្កើនជំនាញឱ្យមានសមត្ថភាពខ្ពស់ស្របទៅនឹងឆ្នាំ២០១២ ក្នុងការបើកចំហរព្រំដែនអាស៊ានដើម្បីប្រកួតប្រជែងទីផ្សារពលកម្មទៅលើផ្នែកសំណង់ អគ្គីសនី...។ល។ ព្រោះការបើកចំហរព្រំដែនគឺយើងអាចទៅរកការងារធ្វើនៅស្រុកគេ ហើយគេអាចមករកស៊ីស្រុកយើង និងប្រាក់ខែរបស់កម្មករជំនាញច្រើនជាងប្រាក់ខែរបស់វិស្វករទើបតែបញ្ចប់ការសិក្សា ។ ឯកឧត្តម ក៏បានលើកឡើងពីរូបឯកឧត្តមផ្ទាល់ពេលចេញពីសាលាបានប្រាក់ខែតិចជាង Supervisor ដែលចេញពីសាលាបច្ចេកទេស ។

**ឯកឧត្តម សុខ អាន :**

ការចាប់អារម្មណ៏របស់ឯកឧត្តម អ៊ុក សូម៉េត ដូចឯកឧត្តម សុន គន្ធរដែរ ដែលសញ្ញាប័ត្របច្ចេកទេសមានប្រាក់ខែច្រើនជាង ដូចនេះយើងនឹងកែទម្រង់ប្រាក់ខែអ្នកបច្ចេកទេសមិនតិចជាងសញ្ញាបត្រ Master Degrce ដើម្បីឱ្យសិស្សចូលរៀន TVET ។ ឯកឧត្តមប្រធាន បានឱ្យអង្គប្រជុំមានយោបល់លើចំណុចអនុសាសន៏ទាំង៧សម្រាប់អនុវត្តឆ្នាំ២០០៨ ។

**ឯកឧត្តម សុន គន្ធរ ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស :**

នៅក្នុងប្រទេសមួយចំនួនធំគេដាក់ឱ្យសហគ្រាសបង់ប្រាក់ ១ ភាគរយ នៃប្រាក់ខែចូលទៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង់ ៤ ភាគរយសម្រាប់បង់ឱ្យផ្ទះកម្មករ ឬបុគ្គលិក។

**ឯកឧត្តម សុខ អាន :**

ក្រុមហ៊ុនផ្សេងៗនៅប្រទេសអាល្លឺម៉ង់បង់មកឱ្យសភាសំរាប់បង់ឱ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធ្វើការបណ្តុះបណ្តាលដោយសភាមានធនាគារផ្ទាល់ខ្លួន ។ ឯកឧត្តមប្រធាន បានស្នើឱ្យសហជីពធ្វើយ៉ាងណាឱ្យក្រុមហ៊ុនចាប់អារម្មណ៏ជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងការបង់ថវិកា។

**ឯកឧត្តម ពេជ សោភ័ន :**

ឯកឧត្តមបានបញ្ជាក់ថា គម្រោងរៀបចំដំណើរការ National Levy Grant System គឺដើម្បីជួយផ្តល់បរិវញ្ញប្បទានសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនេះ មានតាំងតែពីអណត្តិនៃ NTB ចាស់ដែលមានឯកឧត្តម ប៉ុក ថន ជាប្រធាន ហើយគម្រោងនេះមានប្រតិកម្មជាខ្លាំងពីបណ្តានិយោជក។ ដោយសារជំនាញការបានរកឃើញពីចំនុចខ្សោយរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាលអណត្តិមុន ដែល NTB គ្មានអំណាច ហើយប្រធានក៏គ្មានសិទ្ធិអំណាចខ្លាំង ទីពីរ NTB គ្មានលុយសំរាប់ដំណើរការធ្វើឱ្យបានជោគជ័យ ដូចនេះគេសំណូមពរឱ្យពង្រឹងបញ្ហានេះឡើងវិញឥឡូវយើងបានពង្រឹងហើយដោយប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាលជាឧបនាយករដ្ឋមន្ត្រី យើងគិតថាអ្វីដែលដាក់ទៅនឹងអាចចេញបានទើបបានយកបញ្ហានេះ មកពិនិត្យឡើងវិញដោយយើងមានជំនាញការ ២ នាក់ ជួយកែតម្រូវដើម្បីដាក់ជូនពិនិត្យពិភាក្សាសំរេចឆ្លងឱ្យចេញ ដើម្បីឱ្យស្របនឹងគោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។ កន្លងមករាល់ការចំណាយសំរាប់បណ្តុះបណ្តាលគឺរ៉ាប់រងមូលនិធិពីរដ្ឋាភិបាល ចំណែកអ្នកដែលប្រើប្រាស់ពលករ (និយោជក) សហគមន៍ និងអ្នកដែលទទួលការបណ្តុះបណ្តាលជាអ្នកទទួលផល ។

**ឯកឧត្តម សុខ អាន :**

សំណូមពរឱ្យ ឯកឧត្តម **ពេជ សោភ័ន** ធ្វើឱ្យបានសំរេចនូវ National Levy Grant System ប្រទេសដទៃក៏មានប្រព័ន្ធហ្នឹងដែរ បើមិនបង្កើតប្រព័ន្ធហ្នឹង តើ NTB មានលុយមកពីណាសំរាប់ដំណើរការ។ ដូចនេះ NTB ត្រូវមានប្រភពចំណូលដើម្បីឱ្យប្រព័ន្ធ National Levy Grant System មានដំណើរការ ប៉ុន្តែក៏មិនត្រូវយកច្រើនដែរ ព្រោះអាចបណ្តាលឱ្យអ្នកវិនិយោគមិនមកវិនិយោគទុនក្នុងស្រុក។ National Levy Grant System គឺយកតែមួយភាគរយនៃប្រាក់ខែកម្មករទេ ដូចជាបេឡាសន្តិសុខសង្គមដែលមានដំណើរការ ហើយក្រសួងត្រូវរៀបចំអនុក្រឹត្យបង្កើតបេឡា National Levy Grant System ដោយក្រសួងត្រូវចាប់ផ្តើមពិភាក្សាជាមួយសហគ្រាស ក្រុមហ៊ុន សហគ្រិន រៀបចំច្បាប់ និងរៀបចំសិក្ខាសាលាដើម្បីធ្វើចលនាឱ្យពួកគេចូលរួម និងអាចទទួលយកបាន ហើយអាចបង្កើតជាបេឡាមូលនិធិជាតិបណ្តុះបណ្តាល។ ដូចនេះការបណ្តុះបណ្តាលត្រូវតែមានគុណភាពដល់សហគ្រាស ក្រុមហ៊ុន ម្ចាស់ជំនួយ ដើម្បីឱ្យសិក្ខាកាម មានសមត្ថភាព និងជំនាញក្នុងការធ្វើការងារ។

**លោក សុខ ខេង តំណាងវិស័យឧស្សាហកម្មសណ្ឋាគារ :**

ការបង់វិភាគទានមួយភាគរយមិនមានបញ្ហាអ្វីទេ ព្រោះថាក្រុមហ៊ុនក៏ចំណាយថវិកាក្នុងការផ្សព្វផ្សាយជ្រើសរើសបុគ្គលិកដែរ បើមានអ្នកផ្គត់ផ្គង់ស្រាប់ក្រុមហ៊ុនក៏ព្រមបង់ដែរ ។

**ឯកឧត្តម សុខ អាន :**

មួយភាគរយនៃប្រាក់ខែដែលត្រូវបើកឱ្យកម្មករ ឬមួយភាគរយលើអ្វី ?

**ឯកឧត្តម ជួប សំអាត :**

បានបញ្ជាក់អំពីស្ថានភាពក្រុមហ៊ុនដូចជា សហគ្រាសទាំងអស់បិទបញ្ជីចុងឆ្នាំមានលទ្ធភាពដែលត្រូវពិនិត្យចំណេញដុលដែលក្នុងនោះមាន (១.រំលួស ២.បេឡាអភិវឌ្ឍន៍សហគ្រាស ៣. បេឡាហានិភ័យ ៤.បេឡារ៉ាប់រងសង្គម ៥.ពន្ធលើប្រាក់ចំណូល ៦.ការបង្កើតបេឡាអភិវឌ្ឍន៍សង្គម) ចំពោះបេឡាអភិវឌ្ឍន៍សង្គម គឺកាត់ចេញពីចំណេញដុល ដែលគេបង់ប៉ុន្មានតាមការស្ម័គ្រចិត្តរបស់គេ ។

**ឯកឧត្តម សុខ អាន :**

ពង្រាងច្បាប់ National Levy Grant System គឺយើងត្រូវពិចារណាច្រើនទៀតទំរាំរៀបចំរួចស្រេច ហើយផ្ញើរមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរេចតែធ្វើយ៉ាងណាឱ្យមានការចរចារយល់ព្រមសម្រួលឱ្យអនុវត្តបានដោយសហជីពសហគមន៍ ជួយឱ្យសហគ្រាសជួយក្នុងការបង់ ហើយត្រូវការពេលវេលាក្នុងការពិភាក្សាជាមួយក្រុមហ៊ុនឯកជនក្នុងប្រទេស ។

**ឯកឧត្តម ឡា ណារ៉ាត :**

សំខាន់ឱ្យតែច្បាប់ និងអនុក្រឹត្យមាន ដូចនេះវិស័យឯកជនត្រូវតែគោរពតាមច្បាប់របស់រាជរដ្ឋាភិបាល ឯការរៀបចំកំណត់ថាយកប៉ុន្មានគឺអាស្រ័យទៅលើអនុក្រឹត្យ ។ ចំពោះអនុសាសន៍ ឆ្នាំ២០០៨ នៃចំនុចទី១ និង ទី២ ដែលនិយាយអំពី ១- ពង្រឹង ទំនាក់ទំនងរវាង TVET និងសហគ្រាស និងអនុម័តក្របខ័ណ្ឌគុណវឌ្ឍន៍ជាតិបណ្តុះបណ្តាល ២-បង្កើនល្បឿនអភិវឌ្ឍន៍ស្តង់ដាជាតិសមត្ថភាពសំរាប់ផ្នែកសំលៀកបំពាក់ និងបដិសណ្ឋាកិច្ចគឺដូចគ្នាមានលក្ខណៈតែមួយ ។ បច្ចុប្បន្នគេដើរតាមនិន្នាការសិស្ស និស្សិតដែលពូកែគឺក្រុមហ៊ុនឯកជនទៅទាក់ទងនឹងសាលា ដើម្បីឱ្យមកបំរើការងារនៅក្រុមហ៊ុនតែម្តង ដូច្នេះធ្វើយ៉ាងណាឱ្យការបណ្តុះបណ្តាលរួចមានការងារធ្វើដោយឱ្យអ្នកគ្រប់គ្រងមានបទពិសោធន៍ច្រើន ក្នុងការគ្រប់គ្រងការបណ្តុះបណ្តាល ។

**ឯកឧត្តម សុខ អាន :**

សិស្សភាគច្រើនលើសលុបដែលជាប់ទុតិយភូមិមានគំនិតចង់បន្តនៅ Academic ច្រើនជាងចូលទៅសិក្សានៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ឥឡូវមិនភ័យព្រួយខ្វះសិស្សរៀនខាង Academic ទេ យើងត្រូវធ្វើឱ្យសិស្សទៅសិក្សានៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈព្រោះសិស្សភាគច្រើនចង់ទៅបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតជាង គ្មាននរណាចង់ទៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប៉ុន្មានឡើយ។

**ឯកឧត្តម ពេជ សោភ័ន :**

ឯកឧត្តមបានលើកឡើងនូវចំនុចទី២នៃអនុសាសន៍ឆ្នាំ២០០៨ ទាក់ទងទៅនឹងបង្កើនល្បឿនអភិវឌ្ឍន៍ស្តង់ដាជាតិសមត្ថភាពសំរាប់ផ្នែកសំលៀកបំពាក់ និងបដិសណ្ឋារកិច្ច ព្រោះវិស័យទាំងពីរនេះកំពុងតែលូតលាស់ខ្លាំងនៅស្រុកខ្មែរ និងសព្វថ្ងៃ USAID កំពុងជួយខាងសំលៀកបំពាក់ហើយបានសហការណ៍ជាមួយក្រសួងរួចហើយ។

**ឯកឧត្តម សុខ អាន :**

ឯកឧត្តមប្រធាន បានចាប់អារម្មណ៍ពីការលូតលាស់ផ្នែកសំលៀកបំពាក់ និងទេសចរណ៍នៅប្រទេសកម្ពុជា រីឯកសិកម្មយើងមិនទាន់បានធ្វើស្តង់ដានៅឡើយ ចាំថ្ងៃក្រោយឈានទៅផ្នែកកសិកម្ម ។ ឥឡូវយើងអនុម័តអនុសាសន៍ឆ្នាំ២០០៨ ។

**របៀបវារៈទី ៣ :**

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានប្រគល់តួនាទីជូន ឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល ធ្វើការបង្ហាញស្តីពីរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ភារកិច្ច និងសមាសភាពអនុគណៈកម្មការនានា និងសេចក្តីព្រាងបង្កើតភ្នាក់ងារជាតិមុខរបរ ។ ឯឧត្តម បានស្នើសុំបញ្ចូលឯឧត្តម សុន គន្ធរ និងតំណាង ADB ចូលជាសមាជិក NTB និងសុំបញ្ចូលតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារចូលជាសមាជិកអនុគណៈកម្មការទី ១ ។

**ឯកឧត្តម សុខ អាន ៖**

សូមឱ្យអង្គប្រជុំចាប់អារម្មណ៍ទៅលើចំនុចទាំងអស់នេះ

១-ស្តង់ដាជាតិសមត្ថភាពមានប្រយោជន៍សំរាប់គ្រប់គ្រងសហគ្រាស

២-Accreditation មានពីរគឺ Academic ( ACC ) និង TVET

៣-អនុគណៈកម្មការព័ត៌មានទីផ្សារការងារ និងភ្នាក់ងារជាតិមុខរបរខុសគ្នាដូចម្តេច?

**ឯកឧត្តម ពេជ សោភ័ន ៖**

-អនុគណៈកម្មការពត៌មានទីផ្សារការងារជាអនុគណៈកម្មការរបស់ NTB ជាអ្នកទទួលខុសត្រូវដើម្បីរៀបចំរាយការណ៍ជូន NTB ក្នុងការសំរេច ។

-ចំណែកឯភ្នាក់ងារជាតិមុខរបរ (National Employment Agency) ដែលខ្ញុំបាទនឹងស្នើសុំយោបល់ពីឯកឧត្តមប្រធានអង្គប្រជុំ តើគួរស្ថិតនៅក្នុងការគ្រប់គ្រងកន្លែងណា ? តាមសំណើខ្ញុំបាទ National Employment Agency ស្ថិតនៅក្រោម NTB ហើយដែលមានដំណើរការដូចជាៈ

១.ប្រធានភ្នាក់ងារជាតិមុខរបរត្រូវធ្វើពង្រាងច្បាប់ (Term of References) ដែលអនុម័តដោយប្រធានប្រសិនបើ National Employment Agency ស្ថិតក្រោមប្រធាន NTB ជាអ្នកសំរេច

២. ធ្វើ Management Contract ដើម្បីឱ្យប្រធាន NTB ជាអ្នកសំរេច

៣. អ្នកនៅក្រោមទាំងអស់ត្រូវធ្វើ Job Description ពាក់ព័ន្ធនិងភារកិច្ចរបស់ខ្លួនមួយ

**ឯកឧត្តម សុខ អាន ៖**

យើងឃើញថាអនុគណៈកម្មការមានមុខងារដូចគ្នាតែមួយស្ថិតនៅក្រោមក្របខ័ណ្ឌ NTB មួយទៀតស្ថិតនៅក្នុងក្របខ័ណ្ឌ Special Operating Agency (SOA) ដែលយើងនឹងប្រជុំពេលក្រោយសំរាប់ SOA ។ ឥឡូវខិតខំកែសំរួលឱ្យ NTB មានប្រសិទ្ធិភាពកើនឡើង ព្រោះវាចំមុខសញ្ញាដែលត្រូវធ្វើ គឺការបណ្តុះបណ្តាលជំនាញឱ្យកាន់តែឈានឡើង ។ ឯកឧត្តមប្រធានអង្គប្រជុំ សំណូមឱ្យសមាជិក សមាជិការនៃអង្គប្រជុំមានចំណាប់អារម្មណ៍ និងផ្តល់យោបល់ទៅលើរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាលដែលមានអនុគណៈកម្មការទាំង ៣ នេះ តើសមស្របឬទេ?

**ឯកឧត្តម សុន ចន្ធរ សភាមុខរបរ និង មីក្រូសហគ្រាស ៖**

សព្វថ្ងៃនេះសភាមុខរបរមានភ្នាក់ងាររកការងារធ្វើប៉ុន្តែមិនទាន់ដំណើរការទេ ព្រោះខ្វះធនធានដោយសារគ្មានការគាំទ្រពីនិយោជកក្នុងការជឿទុកចិត្ត ។ អញ្ចឹងហើយបើយើងបង្កើតភ្នាក់ងារជាតិមុខរបរជាការល្អ ព្រោះស្រុកណាក៏គេមានដែរ ប៉ុន្តែបើឯករាជ្យមិនទំនងដែរ ព្រោះប្រើប្រាស់ថវិការបស់រដ្ឋាភិបាលទាំងអស់ ។ ឯកឧត្តម មានចំងល់ថា តើទីភ្នាក់ងារជាតិមុខរបរ ជាពាក្យភាសាអង់គ្លេស National Employment Agency តើខុសគ្នានឹងភ្នាក់ងារជាតិការងារដូចម្តេច? ការងារសំដៅរកការងារធ្វើ រីឯមុខរបរសំដៅលើអ្វី? ។

ដោយអនុគណៈកម្មការទាំងបីមានទំនាក់ទំនងគ្នា ឯកឧត្តមស្នើឱ្យអនុគណៈកម្មការទីពាចូលរួមសកម្មភាពណាមួយក្នុងអនុគណៈកម្មការ ឬមួយបន្ថែមសភាមុខរបរដើម្បីចូលរួម ?

**ឯកឧត្តម សុខ អាន ៖**

មុខរបរ និងការងារពាក្យខ្មែរខុសគ្នាបន្តិច ដូចជា មុខរបរធ្វើស្រែ ធ្វើពាណិជ្ជករ រីឯការងារ ឧទាហរណ៍ ដូចជាការងារ

ជាអគ្គនាយក ។ តាមអនុសាសន៍ ឯកឧត្តម ប្រធានអង្គប្រជុំ យើងគួរតែដាក់ថា " ទីភ្នាក់ងារជាតិមុខរបរ និងការងារ " ។

**ឯកឧត្តម ពេជ សោភ័ន :**

ឯកឧត្តម សំដែងនូវការស្វាគមន៍ចំពោះឯកឧត្តម សុន គន្ធរ និងសុំឱ្យសភាមុខរបរចូលរួមទាំងពីរអនុគណៈកម្មការក៏បាន ហើយក្រៅពីសភាមុខរបរ ប្រសិនបើមានក្រសួងដ៏ទៃទៀតស្ម័គ្រចិត្តចូលរួមយើងស្វាគមន៍ទាំងអស់ ព្រោះចូលមកជួយធ្វើការក្នុងការធ្វើពង្រាងមួយ ដើម្បីដាក់ជូន National Training Board ដដែលទេ ។ ចំណែកពាក្យថាមុខរបរ និងការងារនៅក្នុងភ្នាក់ងារជាតិមុខរបរ យើងមិនគ្រាន់តែធ្វើការងាររកមុខរបរឱ្យអ្នករកការងារធ្វើទេ ( មិនមែន Job Placement) គឺយើងបានផ្តោតព័ត៌មានដែលពាក់ព័ន្ធពីរឿងបញ្ហាមុខរបរទាំងអស់ Career និង Occupation ដែលជាគោលដៅថ្ងៃក្រោយ មិនមែនផ្សព្វផ្សាយឱ្យយុវជនយល់ពីរឿងការងារទេ គឺយល់ពីរឿង Career និង Professional ដូចនេះ យើងកំណត់យកពាក្យ Employment នេះឡើង ។

**ឯកឧត្តម សុខ អាន :**

ដោយសារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាម្ចាស់ស្រាប់ យើងដាក់ "គណៈកម្មាធិការជាតិមុខរបរ និងការងារ" បានន័យថាយើងគិតគូរពីមុខរបរ ហើយយើងគិតគូពីការងារផងដែរ ។

**ឯកឧត្តម តិច សំណាង :**

កន្លងមកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា (ACC) យើងបានធ្វើផែនការពង្រឹងគុណភាពផ្នែកអប់រំទូទាំងប្រទេស ។ ដើម្បីឱ្យមានអត្ថប្រយោជន៍ត្រូវធ្វើឱ្យគេទទួលស្គាល់ស្ថាប័នបណ្តុះបណ្តាល ដើម្បីឱ្យការបណ្តុះបណ្តាលរួចសិក្ខាកាមមានការងារធ្វើ ។ អញ្ជឹងបើគេទទួលស្គាល់ស្ថាប័នគុណភាពអប់រំនៅកម្ពុជាហើយនោះ យើងនឹងអាចដំណើរការអនុគណៈកម្មការស្តង់ដាជាតិសមត្ថភាព ព្រោះគេអាចធ្វើតេស្តិ៍ទៅលើសមត្ថភាពជំនាញរបស់គាត់ ។

**ប្រធានអង្គការ UNESCO :**

- គាំទ្រដែលប្រធានអនុគណៈកម្មការជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្ទាល់
- សំណូមពរក្រសួងអប់រំ យុវជន និង កីឡា ដែលជាអ្នកជំនាញចូលជាសមាជិកនៃអនុគណៈកម្មការទី១ ផងដែរ

**ឯកឧត្តម ពេជ សោភ័ន :**

សូមជំរាបជូនលោកប្រធាន UNESCO ថា នៅក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសាលា ២ ជាសមាជិករបស់ UNEVOC ហើយនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏ជាសមាជិករបស់ UNEVOC ដែរ ព្រោះ TVET បានផ្តាច់ចេញពីក្រសួងអប់រំ យុវជន និងកីឡា ។ ឯកឧត្តម សុំឱ្យតំណាង ADB រាយការណ៍ជូនប្រធាន Resident ថារដ្ឋាភិបាលបានដាក់សារៈសំខាន់ទៅផ្នែក TVET ដូចដែលឯឧត្តមប្រធាន NTB ក៏ដូចជាសមាជិកជាច្រើនបានលើកឡើង ដូចនេះសូមឱ្យ ADB នៅពេលបន្តគំរោងគិតគូរបន្តដល់ TVET ហើយឯកឧត្តមមានជំនឿថា មកដល់ពេលនេះមិនទាន់មានស្ថាបន័ណាធ្វើស្តង់ដាចេញទេ មានតែ TVET ទេ ដែលបានធ្វើស្តង់ដាជាង ៣០ មុខរបរ ប៉ុន្តែ TVET មិនទាន់បានដាក់ឆ្លងនៅឡើយ ព្រោះថ្មីៗនេះ ILO Bangkok កំពុងជួយធ្វើក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (National Qualification Framework, NQF) ការគិតពីកំរិតនៃគុណវុឌ្ឍិជាតិមាន ២ បែបៈ ១.តាម TVET និង២. បញ្ចូល TVET និង Academic ។ បើយើងធ្វើ TVET បញ្ចូលគ្នានឹង Academic អាចមាន ៧ កំរិតដែលមានៈ កំរិត ១. ២. ៣ Certificate កំរិត ៤ Diploma កំរិត ៥ Bachelor កំរិត ៦ Master និងកំរិត ៧ Ph.D ។

**ឯកឧត្តម សុខ អាន :**

-TVET ខុសពីវិស្វកម្ម ដោយ TVET ជាកន្លែងសំរាប់បណ្តុះបណ្តាលមិនត្រឹមតែវិស្វករទេ គឺបណ្តុះបណ្តាលគ្រប់ជំនាញដែលទីផ្សារត្រូវការទៅតាមថ្នាក់និមួយៗ និងបណ្តុះបណ្តាលដើម្បីធានាការងារនៅក្នុងសង្គមឱ្យបានល្អ ។

-យើងត្រូវបញ្ចូលក្រសួងអប់រំ យុវជន និង កីឡា ចូលក្នុងអនុគណៈកម្មការទាំង៣ ឬមួយចូលជាអនុប្រធានក្នុងអនុគណៈកម្មការព័ត៌មានទីផ្សារការងារ និងបញ្ចូល CDC ក្នុងអនុគណៈកម្មការនេះផង ហើយតំណាងមីក្រូសហគ្រាសជាសមាជិកក្នុងអនុគណៈកម្មការស្តង់ដាជាតិសមត្ថភាព និងធ្វើតេស្ត៍ និងអនុគណៈកម្មការទទួលស្គាល់កម្មវិធី វគ្គ និងគ្រឹះស្ថានរបស់ TVET ។

**លោក សុខ ខេង តំណាងវិស័យឧស្សាហកម្ម សណ្ឋាគារ :**

លោកមានចំងល់អំពីការបង្កើតអភិវឌ្ឍន៍កម្មវិធីសិក្សាយ៉ាងដូចម្តេចដែរ ដែលពាក់ព័ន្ធទៅនឹងអនុគណៈកម្មការទី១ ?

**ឯកឧត្តម ពេជ សោភ័ន :**

អនុគណៈកម្មការទី១ ដែលត្រូវរៀបចំអភិវឌ្ឍន៍ស្តង់ដា ចេញពីស្តង់ដាបានយើងអភិវឌ្ឍន៍កម្មវិធីសិក្សា ដូចនេះការអភិវឌ្ឍន៍កម្មវិធីសិក្សាចាំបាច់ឱ្យសាលានិមួយៗសង្ខេបឱ្យមាន Syllabus ហើយ TVET ទាមទារឱ្យទីផ្សារទទួលស្គាល់ព្រោះថា TVET បណ្តុះបណ្តាលដើម្បីឱ្យទីផ្សារ ដូច្នេះចាំបាច់ទីផ្សារត្រូវតែទទួលស្គាល់ការបណ្តុះបណ្តាលរបស់ TVET ។

**លោក ពិន សារពេជ្ជ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៃអង្គការដើម្បីភាពញញឹមកុមារ :**

លោកបានបង្ហាញពីបេក្ខភាពក្នុងការចូលរួមជាសមាជិកក្នុងគណៈកម្មការស្តង់ដាជាតិសមត្ថភាព ព្រោះថាខាងសាលាបានធ្វើការជាមួយស្ថាប័នជាច្រើននៅអឺរ៉ុប ជាពិសេសលើផ្នែកសណ្ឋាគារ ហើយសាលានេះអាចនៅជាស្តង់ដាជាតិមួយដែរ ។

**ឯកឧត្តម ពេជ សោភ័ន :**

ឯកឧត្តមបានជំរាបជូននូវរបៀបវារៈបន្តទាក់ទងនឹងផ្នែក២ធំៗគឺ :

១. ពាក់ព័ន្ធព័ត៌មានទីផ្សារការងារ និងប្រព័ន្ធព័ត៌មានទីផ្សារការងារ

២. បង្ហាញជូនពីគំរោងដែលយើងបានគិតគូរដើម្បីរៀបចំក្នុងការបង្កើតភ្នាក់ងារជាតិមុខរបរ និងការងារក្នុងព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តម សុខ អាន :**

តើយើងដាក់ National Employment Agency នៅក្នុងគណៈកម្មាធិការជាតិបណ្តុះបណ្តាល ឬដាក់ក្នុង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ? ហើយការងារទំនាក់ទំនងមានប្រទេសអាឡឺម៉ង់មាន ADB , UNESCO ក៏ជួយ ដែរ យើងសង្ឃឹមច្រើនថានឹងអាចឈានទៅមុខបាន ការប្រជុំសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសអាឡឺម៉ង់ និងកម្ពុជា។

ដោយប្រទេសអាឡឺម៉ង់យល់ព្រមទទួលយក National Employment Agency ហើយ UNESCO បានចាត់ទុក National Employment Agency ជាបញ្ហាអាទិភាពដែលត្រូវដោះស្រាយ ចំណែកឯ ADB បានជួយស្រាប់ហើយ ដូចនេះ NTB ជាអ្នកសម្របសម្រួល ។

**ប្រធានអង្គការ** UNESCO **:**

បានផ្តល់យោបល់ថា យើងគួរតែដាក់ National Employment Agency នៅក្នុង National Training Board ព្រោះវាងាយស្រួលក្នុងការគ្រប់គ្រងការងារ ។ ភ្នាក់ងារជាតិមុខរបរ និងការងារ គួរយកគំរូតាមបណ្តាប្រទេសនានា ដូចជាប្រទេសជប៉ុនក្នុងការគ្រប់គ្រងភ្នាក់ងារជាតិមុខរបរ និងការងារឱ្យបានល្អប្រសើរ ដូចជាការងារកិច្ចការសង្គម និងកត្តាផ្សេងៗដែលទាក់ទង ហើយភ្នាក់ងារត្រូវតែធ្វើការងារជាមួយពួកមានជំនាញមុខរបរ (Career Expert) តាមរយៈធ្វើសន្និបាតក្នុងប្រទេសកម្ពុជា ដើម្បីងាយស្រួលក្នុងការផ្លាស់ប្តូរគំនិតយោបល់គ្នាទៅវិញទៅមក។

**ឯកឧត្តម ឡា ណារ៉េត :**

បានផ្តល់យោបល់ថា រចនាសម្ព័ន្ធរបស់ National Training Board មើលទៅហាក់មានសញ្ញាច្បាស់លាស់ យើងអាចចាត់ទុកថា NTB ជាទីប្រឹក្សាជាន់ខ្ពស់។ NTB បង្កើតឡើងសិក្សាពោរពេញទៅដោយការរៀបចំគោលនយោបាយ គួរតុបតែងយ៉ាងណាដើម្បីឱ្យវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានដំណើរការល្អ ប៉ុន្តែអ្នកអនុវត្តន៍ អ្នកទទួលលទ្ធផល គោលការណ៍នៃការស្រាវជ្រាវ គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រោះវាមានឥទ្ធិពលផ្ទាល់ ទៅនឹងប្រជាជន អ្នកប្រើប្រាស់ពលកម្មនៅក្នុងប្រទេស និងក្រៅប្រទេស ។ អញ្ចឹងខ្ញុំយល់ថាភ្នាក់ងារជាតិមុខរបរ និងការងារ គួរនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រីឯអនុគណៈកម្មការទាំង ៣ ជាអង្គការចាត់តាំងសកម្មភាពរបស់ NTB ដែលពោរពេញទៅដោយភារកិច្ច តួនាទីស្រាវជ្រាវរៀបចំបរិស្ថាន ។

**ឯកឧត្តម សុន គន្ធរ ប្រធានសភាមុខរបរ និង មីក្រូសហគ្រាស :**

ភ្នាក់ងារជាតិមុខរបរ និងការងារវាបំរើឱ្យផលប្រយោជន៍សាធារណៈអញ្ចឹងវាអាចទៅជាភ្នាក់ងារប្រតិបត្តការពិសេស (SOA)ជាទំនោរដែលដៃគូអភិវឌ្ឍន៍ចង់ជួយយើងតែតាមការពិតការងារទាំងអស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាអ្នកធ្វើ។

**ឯកឧត្តម ពេជ សោភ័ន :**

ឆ្លើយតបនឹងមតិមួយចំនួនដែលបានលើកឡើង ឯកឧត្តមបានរំលឹកទាក់ទងនឹងបទពិសោធន៍ចាស់នូវអ្វីដែល Board បានសំរេចហើយបែរជាអនុវត្តន៍មិនបាន ព្រោះថា NTB ខ្សោយដោយសារមិនមានថវិកាសំរាប់ដំណើរការ។ បើដាក់ភ្នាក់ងារជាតិមុខរបរ និងការងារ ក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទោះជាឯកឧត្តមផ្ទាល់ជាអ្នកទទួលខុសត្រូវ តែនេះជាបញ្ហា Challenge ធំណាស់ ហើយជាឱកាសមួយដែល Chairman គឺឯកឧត្តមឧបនាយករដ្ឋមន្ត្រីជួយរុញឱ្យចេញ ដូច្នេះបើមិនដាក់ក្រោម NTB ទេ ដំណើរការទៅអាចជួបឧបសគ្គ និងមានបញ្ហាច្រើន។ តែបើដាក់ឱ្យក្រោម NTB នឹងមានការឧបត្ថម្ភពិសេស គឺមានការអន្តរាគមន៍គ្រប់ផ្នែកទាំងអស់ដែលជាសមាជិកនៅតាមឯកជនតាម NGOs ជាពិសេសក្រសួងដែលពាក់ព័ន្ធ វាដូចជាកំលាំងមួយជួយដូចជាកូនដែលកើតឡើងដោយមូលគ្នាច្រើន ដូច្នេះកូននេះវាអាចធំធាត់ អាចដើរបាន ។ ផ្ទុយទៅវិញបើគ្រាន់តែបង្កើតហើយដាក់នៅកន្លែងផ្សេងសំរាប់ចិញ្ចឹមមិនដឹងថ្ងៃក្រោយមានលទ្ធភាពចិញ្ចឹម ឬអត់ ។ តាមយោបល់ឯកឧត្តម សំណូមពរឱ្យ Nation Employment Agency ស្ថិតនៅក្រោមការដឹកនាំរបស់ National Training Board ។ សព្វថ្ងៃនេះប្រព័ន្ធ TVET នៅកម្ពុជាដើរលឿនជាងប្រទេសផ្សេងៗតាមបែបកំណែទំរង់ស៊ីជំរៅ ប៉ុន្តែអ្វីដែលជា

ផ្លែផ្កាមិនទាន់មាន ដូចនេះវាទាមទារ Board ឱ្យខ្លាំង។

**លទ្ធផលនៃអង្គប្រជុំ :**

ឆ្លងតាមបទបង្ហាញលើរបៀបវារៈទី១ ទី២ និងទី៣ អង្គប្រជុំបានឯកភាពការងារមួយចំនួនដូចខាងក្រោម:

១- បានសំរេចអនុម័តលើអនុសាសន៍ទាំង ៧ ចំនុច សម្រាប់ការអនុវត្តឆ្នាំ២០០៨

២- បញ្ចូលឯកឧត្តម សុន គន្ធរ ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស និងតំណាង ADB ចូលជាសមាជិក NTB

៣- អនុម័តលើរចនាសម្ព័ន្ធនៃគណ:កម្មាធិកាជាតិបណ្តុះបណ្តាលដែលមាន ៣ អនុគណ:កម្មការ

៤- បញ្ចូលតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការដើម្បីភាពញញឹមនៃកុមារចូលជាសមាជិកអនុគណ:កម្មការស្តង់ដាជាតិសមត្ថភាព និងធ្វើតេស្ត

៥- បញ្ចូលតំណាងក្រសួងអប់រំ យុវជន និង កីឡា ជាអនុប្រធានក្នុងអនុគណ:កម្មការព័ត៌មានទីផ្សារការងារ

៦- បញ្ចូលតំណាងមីក្រូសហគ្រាស ជាសមាជិកនៃអនុគណ:កម្មការស្តង់ដាជាតិសមត្ថភាព និងក្នុងអនុគណ:កម្មការទទួលស្គាល់កម្មវិធី វគ្គ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវ:

៧- អនុម័តការបង្កើតភ្នាក់ងារជាតិមុខរបរ និងការងារ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណ:កម្មាធិការជាតិបណ្តុះបណ្តាល

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ និងដប់ប្រាំនាទីយប់នា ថ្ងៃ ខែ ឆ្នាំដដែលក្រោមបរិយាកាសស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់ ។

រាជធានី.ភ្នំពេញថ្ងៃទី............ខែ ............ឆ្នាំ២០០៨

លេខាកត់ត្រា

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

ហ៊ីង ស៊ីដេត